# អនុក្រឹត្យលេខ ៦៦ អនក្រ.បក
## ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិ វរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងរបៀបប្រគល់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណូមពរចាំបាច់ក្នុងការលើកទឹកចិត្ត និងដើម្បីរៀបចំការជូនគ្រឿងឥស្សរិយយសរបស់ជាតិមានភាពសុក្រឹតល្អ

### សំរេច

**មាត្រា ១ .–**

បង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន មន្ត្រីរាជការ ដែលត្រូវផ្តល់ជូនគ្រឿងឥស្សរិយយស ។

**មាត្រា ២ .–**

សមាសភាពគណៈកម្មការនេះ រួមមាន :

| | |
|---|---|
| ១-ឯកឧត្តម អគ្គលេខាធិការរាជរដ្ឋាភិបាល | ប្រធាន |
| ២-ឯកឧត្តម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | អនុប្រធាន |
| ៣-ឯកឧត្តម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ មួយរូប | សមាជិក |
| ៤-ឯកឧត្តម រដ្ឋលេខាធិការក្រសួងការពារជាតិ មួយរូប | សមាជិក |
| ៥-លោកប្រធាននាយកដ្ឋានឥស្សរិយយស នៃទីស្តីការគណៈរដ្ឋមន្ត្រី | លេខាធិការ |

**មាត្រា ៣ .–**

គណៈកម្មការនេះ មានភារកិច្ច :

-សម្រេចគោលន័យ សំរាប់ការទទួលគ្រឿងឥស្សរិយយសចំពោះមន្ត្រីរាជការ

-ពិនិត្យលក្ខណសម្បត្តិវរជនដែលមានស្នាដៃ និងគុណបំណាច់ពិសេសក្នុងបុព្វហេតុការពារបូរណភាពទឹកដី ឯករាជ្យ សន្តិភាព ប្រជាធិបតេយ្យ និងក្នុងការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ

-ពិនិត្យចំនួនបញ្ជីពណ្ណកសម្បត្តិ មន្ត្រីរាជការ ទាំងឡាយដែលក្រសួង ស្ថាប័នរដ្ឋនានា ស្នើសុំគ្រឿងឥស្សរិយយស

-ពិនិត្យ សំរេច និងធ្វើសំណើជាកំរូនសម្តេចនាយករដ្ឋមន្ត្រី លើប្រភេទគ្រឿងឥស្សរិយយស តាមចំណាត់ថ្នាក់ ដែលបានបំពេញការងារដើម្បីជាប្រយោជន៍ជាតិ

-ធ្វើសំណើពិសុំគ្រឿងឥស្សរិយយសជូន មន្ត្រីរាជការ ម្តងក្នុង ២ ឆ្នាំម្តង ។

មាត្រា ៤ ._

គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតអោយមានគណៈកម្មការមួយ ដើម្បីពិនិត្យបញ្ជីពណ្ណកសម្បត្តិមន្ត្រីដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស ដែលមានថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ផ្ទាល់ជាប្រធានគណៈកម្មការ និង ថ្នាក់ដឹកនាំអង្គភាពសំខាន់ៗ ក្រោមឱវាទក្រសួង ស្ថាប័ន ជាសមាជិក ហើយបញ្ជូនបញ្ជីបេក្ខជនដែលស្នើសុំគ្រឿងឥស្សរិយយសទាំងនោះមកគណៈកម្មការពិនិត្យបញ្ជីពណ្ណកសម្បត្តិបេក្ខជន មន្ត្រីរាជការ ដែលត្រូវផ្តល់ជូនគ្រឿងឥស្សរិយយស ។

មាត្រា ៥ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងសមាសភាពគណៈកម្មការ ដូចមានចែងក្នុងមាត្រា ២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

**អនុក្រឹត្យលេខ ៦៧ អនក្រ.បក**

**ស្តីពីការលុបអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០០**

**ស្តីពីការរៀបចំព្រំប្រទល់ដី និងសំណង់ នៅខេត្ត សៀមរាប អង្គរ**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com